ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ:៣៩៦/៣-៥-២០១១

សាលដីកា បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែល លេខ:៧៣ក្រIVអ/៣១-៧-២០១២ ប្រកាសឱ្យប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណ:នៅសាលាឧទ្ធរណ៍ នាថ្ងៃទី៣១-៧-២០១២ ដែលមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:៣៩៦ ចុះថ្ងៃទី៣-៥-២០១១ រវាង ៖

១-ជនជាប់ចោទឈ្មោះ [redacted]គៀង ហៅ ញ៉ៀវ ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ មុខរបរអ្នកម៉ៅការបោះពុម្ព កើតនៅភូមិពោធិ៍ស្វាង ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះលេខ[redacted]ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) នៅលីវ ទោសពីមុនគ្មាន ។

ឃាត់ខ្លួនថ្ងៃទី២៧.៦.២០១០ និងឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ:៩២៤ តព្រ ថ្ងៃទី០២.៧.២០១០

មេធាវីការពារលោក [redacted]វិនីតា

ជាប់ចោទពីបទ: ក្លែងក្រដាសប្រាក់ និង ចរាចរនូវក្រដាសប្រាក់ក្លែងក្លាយដោយចេតនា ប្រព្រឹត្តនៅចំណុចសាលារៀនសាម៉ែន ផ្លូវលេខ៣១៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពី

២៩៥



Scanned with CamScanner

ថ្ងៃទី២៧-៦-២០១០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦៥ និងមាត្រា៦៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា ។

២-ជនជាប់ចោទឈ្មោះ [redacted] សារ៉ាត់ ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរសន្តិសុខផ្សារលូប្រាំ កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះជួល ភូមិ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០៣នាក់ ទោសពីមុនគ្មាន ។

ឃាត់ខ្លួនថ្ងៃទី២៧.៦.២០១០ និងឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ:៨២៧ តព្រ ថ្ងៃទី០២.៧.២០១០

មេធាវីការពារលោកស្រី [redacted] ាសីភ័ក្ត

៣-ជនជាប់ចោទឈ្មោះ [redacted] សុខហ៊ី ហៅ ខ្មៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ កើតនៅភូមិព្រៃគី ឃុំព្រៃគី ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង ទីលំនៅមុនពេលឃាត់ខ្លួន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះពាង លៀន មានកូន០២នាក់ ទោសពីមុនគ្មាន ។

ឃាត់ខ្លួនថ្ងៃទី២៧.៦.២០១០ និងឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ:៨២៥ តព្រ ថ្ងៃទី០២.៧.២០១០

មេធាវីការពារលោក [redacted] ភា

៤-ជនជាប់ចោទឈ្មោះ [redacted] ផាន ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ កើតនៅភូមិសោម ឃុំសោម ស្រុកគីរីវង្ស ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះជួល [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្តីឈ្មោះ [redacted] (ស) មានកូន០៥នាក់ ទោសពីមុនគ្មាន ។

ឃាត់ខ្លួនថ្ងៃទី២៧.៦.២០១០ និងឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ:៨២៦ តព្រ ថ្ងៃទី០២.៧.២០១០ ។

មេធាវីការពារលោកស្រី [redacted] រាសីភ័ក្ត

ជាប់ចោទពីបទ: ចរាចរនូវក្រដាសប្រាក់ក្លែងក្លាយដោយចេតនា ប្រព្រឹត្តនៅចំណុចសាលារៀនសាម៉ែន ផ្លូវលេខ៣១៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧-៦-២០១០ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា ។ ៤៩៦



Scanned with CamScanner

ឯរឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី២៧-៦-២០១០ វេលាម៉ោង១៤និង០០នាទី ការិយាល័យពត៌មានទូទៅនៃស្នងការដ្ឋានពត៌មាន និង សន្តិសុខកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានធ្វើការចុះបង្ក្រាបករណីផលិត និង ចរាចរក្រដាសប្រាក់ក្លែងក្លាយ នៅចំណុចមុខសាលារៀនសាម៉ែន ផ្លូវលេខ៣១៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ហើយបានធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន០៤នាក់ ឈ្មោះ [redacted]គៀង ហៅ ញ៉េវ ភេទប្រុស អាយុ២៤ឆ្នាំ ឈ្មោះ [redacted]សារ៉ាត់ ភេទប្រុស អាយុ២៨ឆ្នាំ ឈ្មោះ [redacted]សុខហ៊ី ភេទប្រុស អាយុ២៧ឆ្នាំ និងឈ្មោះ [redacted] ផាន ភេទស្រី អាយុ៥៥ឆ្នាំ និង ចាប់យកវត្ថុតាងមានប្រាក់ដុល្លាក្លែងក្លាយចំនួន៣០.០០០$(បីម៉ឺនដុល្លាអាមេរិក) ក្រដាសប្រាក់រៀលក្លែងក្លាយចំនួន៤០.០០០.០០០រៀល(សែសិបលានរៀល) ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ១១ក្រ១ ចុះថ្ងៃទី១៥-២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅៈ

១-កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] គៀង ហៅ ញ៉េវ ភេទប្រុស អាយុ២៤ឆ្នាំ ឈ្មោះ [redacted]សារ៉ាត់ ភេទប្រុស អាយុ២៨ឆ្នាំ ឈ្មោះ [redacted]សុខហ៊ី ហៅ ខ្មៅ ភេទប្រុស អាយុ២៧ឆ្នាំ និងឈ្មោះ [redacted] ផាន ភេទស្រី អាយុ៥៥ឆ្នាំ ពីបទ ក្លែងក្រដាសប្រាក់ និង ចរាចរនូវក្រដាសប្រាក់ក្លែងក្លាយដោយចេតនា ប្រព្រឹត្តនៅចំណុចសាលារៀនសាម៉ែន ផ្លូវលេខ៣១៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧-៦-២០១០ តាមមាត្រា៦៥ និងមាត្រា៦៦ នៃច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា ទៅជាបទ ក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល បទក្លែងបន្លំរូបិយប័ណ្ណដែលមានតម្លៃនីត្យានុកូល និងបទ ដាក់ឲ្យធ្វើចរាចររូបិយវត្ថុ និង រូបិយប័ណ្ណក្លែងប្រព្រឹត្តនៅចំណុចសាលារៀនសាម៉ែន ផ្លូវលេខ៣១៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧-៦-២០១០ តាមមាត្រា៦៤៥ មាត្រា៦៤៦ និងមាត្រា៦៤៧ នៃក្រមព្រហ្មទណ្ឌ ។

២-ផ្ដន្ទាទោសៈ

ក.ឈ្មោះ [redacted] គៀង ហៅ ញ៉េវ ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល២០(ម្ភៃឆ្នាំ) ពីបទៈ ក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល បទៈ ក្លែងបន្លំរូបិយប័ណ្ណដែលមានតម្លៃនីត្យានុកូល និងបទៈ ដាក់ឲ្យធ្វើចរាចររូបិយវត្ថុ និង រូបិយប័ណ្ណក្លែង តាមមាត្រា៦៤៥ មាត្រា៦៤៦ និងមាត្រា៦៤៧ នៃក្រមព្រហ្មទណ្ឌ ។

ខ.ឈ្មោះ [redacted]សារ៉ាត់ ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ

គ.ឈ្មោះ [redacted] សុខហ៊ី ហៅ ខ្មៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ

៧៤៧

ឃ.ឈ្មោះ [redacted] ផាន ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល៨ឆ្នាំ(ប្រាំបីឆ្នាំ)

ពីបទដាក់ឲ្យធ្វើចរាចររូបិយវត្ថុ និង រូបិយវត្ថុក្លែង ប្រព្រឹត្តនៅចំណុចសាលារៀនសាម៉ែន ផ្លូវលេខ៣១៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧-៦-២០១០ តាមមាត្រា ៦៤៧ នៃក្រមព្រហ្មទណ្ឌ ។

៣-វត្ថុតាងមាន:

ក:

-ក្រដាសប្រាក់ដុល្លាអាមេរិកប្រភេទក្រដាស១០$(ដប់ដុល្លាអាមេរិក)ក្លែងក្លាយ ជាចំនួន ៣០.០០០$(បីម៉ឺនដុល្លាអាមេរិក)

-ក្រដាសប្រាក់រៀលក្លែងក្លាយប្រភេទ១០០០០រៀល(មួយម៉ឺនរៀល)ចំនួន៤០.០០០.០០០ រៀល(សែសិបលានរៀល)

-ក្រដាសប្រាក់បាតថៃក្លែងក្លាយប្រភេទ១០០០បាត(មួយពាន់បាត) ចំនួន៨២.០០០បាត (ប្រាំបីម៉ឺនពីរពាន់បាត)

-ក្រដាសរាមម៉ាក IK Copy paper A470 GSM 500 SHEETS រូបអាត់ប៊ិចមួយចំនួន ក្រដាសរ៉ាម ប្រភេទរលោងពណ៌សមួយចំនួន

-កាបូបពណ៌ខ្មៅសម្រាប់ដាក់ប្រាក់ មានប្រាក់ក្លែងក្លាយលេខៈ ខ ២៦៨៩០៨១៦ ចំនួន ១០០០០រៀល(មួយម៉ឺនរៀល)

-កាបូបពណ៌ស្ទូកូឡាសម្រាប់ដាក់ប្រាក់មួយ មានលុយចំនួន១៨១០០រៀល(មួយម៉ឺនប្រាំបីពាន់មួយរយរៀល)

ត្រូវរឹបអូសបំផ្លាញចោល ។

ខ:

-ម៉ូនីទ័រកុំព្យូទ័រម៉ាក Fujitsu ពណ៌ស ចំនួន០១គ្រឿង ស្កេនន័រម៉ាក HP Scanjet G 3110 ពណ៌សលើខ្មៅក្រោមចំនួន០១គ្រឿង ព្រីនធ័រម៉ាក HP Color Laserjet 1600 ពណ៌សចំនួន០១គ្រឿង ស៊ីភីយូពណ៌ខ្មៅម៉ាក DELL ចំនួន០១គ្រឿង(ខូចគុណភាព) ។

-ម៉ូតូម៉ាក Air BLade ពណ៌សលាយក្រហម ពាក់ស្លាកលេខ ភ្នំពេញ IV-២៩៦២ បាក់ហ្វាំងខាងស្តាំ ផ្នែកខាងមុខ លេខតួ NC 110 AC-003624 ។

-ទូរស័ព្ទសលាយខ្មៅស៊ីមពីរ ផលិតនៅប្រទេសចិន ០១គ្រឿង មានស៊ីម Beeline ។

២៤៨



Scanned with CamScanner

-ទូរស័ព្ទម៉ាកសាមសុង ពណ៌ខ្មៅលាយក្រហម ស៊េរី C278 ចំនួន០១គ្រឿង មានស៊ីមលេខ ០៩២ ១៧៧ ៧៧៨ ។

-ទូរស័ព្ទពណ៌ខ្មៅស៊ីមពីរ ផលិតនៅប្រទេសចិន ម៉ាក Bluetooth ចំនួន០១គ្រឿង មានស៊ីមលេខ ០១៥ ៧៥២ ៣៣៧ និងស៊ីមលេខ០៩៧ ។

ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

៤-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៤.២.២០១១ និង ប្រកាសជាសាធារណៈនៅថ្ងៃទី១៥.២.២០១១ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

-បានឃើញសេចក្តីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] គៀង ហៅ ញ៉ៀវ (អវត្តមាន)

-មេធាវីការពារលោក [redacted] វីនីតា (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] សារ៉ាត់ (អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] ផាន (វត្តមាន)

-មេធាវីការពារលោកស្រី [redacted] រាសីភ័ក្ត (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] សុខហ៊ី ហៅ ខ្មៅ (អវត្តមាន)

-មេធាវីការពារលោក [redacted] ភា (វត្តមាន)

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍ និង សង្ខេបរឿងជូនអង្គសវនាការ

-ប្រធានក្រុមប្រឹក្សាអានចម្លើយឈ្មោះ [redacted] គៀង ហៅ ញ៉ៀវ

-ប្រធានក្រុមប្រឹក្សាអានចម្លើយឈ្មោះ [redacted] សុខហ៊ី ហៅ ខ្មៅ

-ប្រធានក្រុមប្រឹក្សាអានចម្លើយឈ្មោះ [redacted] សារ៉ាត់

-ជនជាប់ចោទឈ្មោះ [redacted] ផាន ឆ្លើយថា: នាងខ្ញុំមិនបានចូលរួមធ្វើសកម្មភាពប្រព្រឹត្តជាមួយឈ្មោះ លាង គៀង ទេ គឺកូននាងខ្ញុំបានប្រព្រឹត្តបទល្មើសចរាចរក្រដាសប្រាក់ក្លែងក្លាយចំនួន៣ដង វាបានប្រាប់ខ្ញុំថាវាឈប់ប្រព្រឹត្តហើយ ។ វាបានទូរស័ព្ទមកខ្ញុំឱ្យយកលុយ១០$ និង លុយខ្មែរ១០០០០៛ ឱ្យប៉េអ៊ឹមមើល ដោយខ្ញុំបានទទួលលុយនេះពីឈ្មោះ [redacted] គៀង ហៅ ញ៉ៀវ ឈ្មោះ [redacted] សារ៉ាត់ ជាកូនខ្ញុំបង្កើត ខ្ញុំរស់នៅជាមួយវាជួយមើលថែចៅ កូនប្រសារខ្ញុំធ្វើការនៅរោងចក្រ ។ ខ្ញុំជួលផ្ទះគេនៅជិតផ្ទះ

៧៥៩

ចំរើន មុនពេលខ្ញុំលើកទូរស័ព្ទឈ្មោះ [redacted] គៀង គាត់បានមករក ចំរើន មុន តែអត់ឃើញក៏ជួបខ្ញុំ ។ នាងខ្ញុំសុំទទួលស្គាល់ថាបានដោះដូរលុយក្លែងក្លាយ តែពុំដែលបានជួបជុំគ្នានៅក្នុងផ្ទះខ្ញុំទេ ខ្ញុំធ្លាប់បានដឹងថាកូនរកស៊ីតែ១លើក គឺពេលហុចលុយហ្នឹង មានលុយបាត លុយដុល្លាក្រដាស១០$ លុយក្លែងដូរ៥០ម៉ឺន ឲ្យ៦ម៉ឺនលុយសុទ្ធ(កូនខ្ញុំប្រាប់) ។

សំណូមពរ សុំលោកតុលាការមេត្តាលើកលែងការចោទប្រកាន់ដល់នាងខ្ញុំផង ។

-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់របាយការណ៍ របស់ប្រធានក្រុមប្រឹក្សា ក្រោយពីបានស្តាប់អំណានជនជាប់ចោទទាំងបីរូបអវត្តមាន ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ផាន មក ឃើញថាបទល្មើសនេះមានធាតុផ្សំដូចតុលាការសាលាដំបូងសម្រេចមែន ការសម្រេចនេះមានលក្ខណៈត្រឹមត្រូវ សុំក្រុមប្រឹក្សាសម្រេចផ្តន្ទាទោសជនជាប់ចោទខាងលើ ឲ្យបានធ្ងន់ធ្ងរ ព្រោះឈ្មោះ [redacted] គៀង គាត់ចេះប្រើតាំងពីរបៀបដាក់ម្សៅធ្វើឲ្យក្រដាសឡើងគ្រើមទៀតផង ។

-មេធាវី [redacted] វិនីតា ការពារឲ្យជនជាប់ចោទឈ្មោះ [redacted] គៀង ហៅ ញៀវ ធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្ញុំប្តឹងឧទ្ធរណ៍មកនេះព្រោះនៅសាលាដំបូង សម្រេចដាក់គុកកូនក្តីខ្ញុំ២០ឆ្នាំធ្ងន់ធ្ងរពេក ។ ទី១ ផ្អែកតាមកំណត់ហេតុនេះកូនក្តីខ្ញុំបានសារភាព ។ ចំណុចមួយទៀតគាត់បានបដិសេធព្រោះទាក់ទងទៅនឹងបទល្មើស ការដាក់ឲ្យប្រើប្រាស់ប្រាក់ក្លែងបន្លំទាំងពីរ គឺទាក់ទងការផលិតលុយក្លែងក្លាយ វាមិនទាន់ពេញលក្ខណៈនៃធាតុផ្សំបទល្មើសទេ ការឆែកឆេរក៏រកមិនឃើញមានហាសឌីសដែលជាភស្តុតាង គឺគ្រាន់តែទាក់ទងនឹងហាសឌីសប៉ុណ្ណោះ ដែលធ្វើឲ្យមានចំណុចសង្ស័យ ភស្តុតាងនេះគឺអត់ឃើញមានប្រដាប់ស្កែនទេ ភស្តុតាងនេះធាតុសត្យានុម័តបាត់បង់ ហើយធាតុអត្តនោម័តក៏មិនអាចដាក់បន្ទុកលើកូនក្តីខ្ញុំបានទេ ។ កូនក្តីខ្ញុំបានសារភាពរហូតនៅគ្រប់ដំណាក់ការសួរចម្លើយ ដោយសារឈ្មោះ វណ្ណា បានសន្យាថាបើព្រមទទួលឆ្លើយសារភាព នោះសមត្ថកិច្ចគេនឹងឲ្យកូនក្តីខ្ញុំនៅក្រៅឃុំ កូនក្តីខ្ញុំបានដឹងថាខ្លួនបានប្រព្រឹត្តខុសច្បាប់ ។

សំណូមពរ សុំក្រុមប្រឹក្សាលុបចោលការសម្រេច ដោយយោងតាមមាត្រា៦៥៥ និង ៦៣៦ នៃក្រមព្រហ្មទណ្ឌ និងសុំសម្រេចដោយយោងតាមមាត្រា៦៤៧ និងមាត្រា៩៣ និង៩៤ នៃក្រមព្រហ្មទណ្ឌ។

-មេធាវីលោក [redacted] ភា ការពារឲ្យជនជាប់ចោទឈ្មោះ [redacted] សុខហ៊ី ធ្វើសេចក្តីសន្និដ្ឋានថា: ពាក់ព័ន្ធការដាក់ទោសកូនក្តីខ្ញុំៗមិនបានប្រព្រឹត្តបទល្មើស ដូចសាលាដំបូងសម្រេចផ្តន្ទាទោសនោះទេ ថ្ងៃ២៥.៦.២០១០ ឈ្មោះ [redacted] គៀង បានទូរស័ព្ទហៅកូនក្តីខ្ញុំមកភ្នំពេញ [redacted] គៀង បានដឹកកេះមួយ គាត់ថាកេះនេះដាក់ឥវ៉ាន់ទេ ថាឲ្យកូនក្តីខ្ញុំអង្គុយចាំ [redacted] គៀង នេះនឹងឲ្យលុយចាយ កូនក្តីខ្ញុំមិនបានដឹងថាជាលុយក្លែងក្លាយទេ ក៏មិនដឹងថាមានទោសដែរ ព្រោះស្មានថាគេរកការងារឲ្យធ្វើ ពេលមកដល់ទើបដឹង



Scanned with CamScanner

ថាជ្រុលខ្លួនចាញ់បោកគេ គាត់គ្មានចេតនាទេ ។ តាមមាត្រា៤ នៃក្រមព្រហ្មទណ្ឌ ការប្រព្រឹត្តដោយគ្មានចេតនា គឺគ្មានទោសទេ ។

សំណូមពរ សុំក្រុមប្រឹក្សាមេត្តាលើកលែងការចោទប្រកាន់លើកូនក្តីខ្ញុំផង ។

-មេធាវីលោកស្រី [redacted] រាសីភ័ក្ក ការពារឲ្យជនជាប់ចោទឈ្មោះ [redacted] សាវ៉ាត់ និងឈ្មោះ [redacted] ផាន ធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្ញុំបានទទួលស្គាល់កំហុសខ្លួនហើយ និង បានបញ្ឈប់អំពីការប្រព្រឹត្តបទល្មើសនេះហើយ ។

សំណូមពរ សុំក្រុមប្រឹក្សាមេត្តាពិចារណាចំពោះកូនក្តីខ្ញុំ ព្រោះគាត់មានវ័យចាស់ណាស់ហើយ ឯឈ្មោះ លឹម សាវ៉ាត់ បានទទួលស្គាល់កំហុសខ្លួន និងដោយសារគាត់មានជីវភាពក្រីក្រមិនបានយល់ដឹងពីបទល្មើសដែលគាត់ប្រព្រឹត្ត សុំក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំផង ។

-ក្រោយពីបានអានរបាយការណ៍

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍

## យល់ឃើញថា ៖

១-បណ្តឹងឧទ្ធរណ៍លេខ:១៦៣ ចុះថ្ងៃទី២-៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ផាន

-បណ្តឹងឧទ្ធរណ៍លេខ:១២៥ ចុះថ្ងៃទី២២-២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] សាវ៉ាត់

-បណ្តឹងឧទ្ធរណ៍លេខ:១២៦ ចុះថ្ងៃទី២២-២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] សុខហ៊ី

-បណ្តឹងឧទ្ធរណ៍លេខ:១២៤ ចុះថ្ងៃទី២២-២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] គៀង

ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

-មេធាវី [redacted] វីនីតា ការពារសិទ្ធិឲ្យជនជាប់ចោទ [redacted] គៀង ។

-មេធាវី [redacted] ភា ការពារសិទ្ធិឲ្យជនជាប់ចោទ [redacted] សុខហ៊ី ។

-មេធាវី [redacted] រាសីភ័ក្ក ការពារសិទ្ធិឲ្យជនជាប់ចោទ [redacted] សាវ៉ាត់ និង [redacted] ផាន ។

២៦១



Scanned with CamScanner

២-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] គៀង ឆ្លើយបដិសេធចម្លើយរបស់ខ្លួននៅសមត្ថកិច្ច PM និងនៅអយ្យការរាជធានីភ្នំពេញថា ខ្លួនជាអ្នកផលិតក្រដាសប្រាក់ក្លែងក្លាយនោះមិនពិតទេ ។ ខ្លួនគ្រាន់តែជាអ្នកទទួលពីឈ្មោះ វណ្ណា(មិនស្គាល់សារពា) ដើម្បីយកទៅចែកចាយបន្តតែប៉ុណ្ណោះ ។ ចម្លើយនេះមិនអាចដោះបន្ទុកបានឡើយ ដោយហេតុថា ចម្លើយរបស់ជនជាប់ចោទនេះនៅអយ្យការ(ឯ.៦) គ្មានការគំរាមកំហែង ឬបង្ខិតបង្ខំឡើយ ។ ជនជាប់ចោទឆ្លើយថា ក្រដាសប្រាក់ក្លែងដែលសមត្ថកិច្ចបង្ក្រាប និង ចាប់យកនៅថ្ងៃ២៧.៦.២០១០ នៅផ្លូវ៣១៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក ក្នុងនោះមានក្រដាសប្រាក់ក្លែង១០ដុល្លាអាមេរិក ចំនួនបីម៉ឺនដុល្លា ក្រដាសប្រាក់១ម៉ឺនរៀល ចំនួន៤០លានរៀល ទាំងអស់នេះខ្លួនជាអ្នកផលិតតែម្នាក់ឯង ។ ឃើញថាមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ឈាង គៀង ពីបទៈ ក្លែងបន្លំរូបិយវត្ថុ និង រូបិយប័ណ្ណបរទេស ។

៣-តាមលិខិតចុះថ្ងៃ១២ កក្កដា ២០១០ របស់អង្គភាពស៊ើបការសម្ងាត់សហរដ្ឋអាមេរិក(ឯ.៤០) បញ្ជាក់ថា តាមសំណើផ្ទៀងផ្ទាត់រូបិយប័ណ្ណរបស់កងរាជអាវុធហត្ថកម្ពុជា ចំពោះក្រដាសប្រាក់១០ដុល្លា FRNS ដែលសង្ស័យថាក្លែងក្លាយចំនួន៣០០០សន្លឹក ជាស៊េរីបោះពុម្ពឆ្នាំ២០០៦ ។ ក្រដាសប្រាក់ទាំងនោះត្រូវបានកំណត់ថាក្លែងក្លាយ ដោយចំណុចក្លែងបន្លំដែលអាចមើលឃើញដូចជា អក្សរបោះពុម្ពតូចៗមិនច្បាស់ គ្មានសរសៃអំបោះសុវត្ថិភាពបញ្ឈរ មានសរសៃអំបោះតូចៗជាច្រើនពណ៌ ។ ដូចនេះរូបិយប័ណ្ណ១០ដុល្លាអាមេរិកចំនួន៣០០០សន្លឹក ជាវត្ថុតាងចាប់យក ជារូបិយប័ណ្ណក្លែងបន្លំ ។

៤-ជនជាប់ចោទឈ្មោះ [redacted] សុខហ៊ី- [redacted] សារ៉ាត់ ទទួលស្គាល់ដូចគ្នាថាពួកខ្លួនជាអ្នកទទួលប្រាក់ក្លែង ជាក្រដាសប្រាក់មួយម៉ឺនរៀល លុយបាតថៃ១០០០បាត និងក្រដាសប្រាក់១០ដុល្លាអាមេរិកពីឈ្មោះ [redacted] គៀង យកទៅឱ្យអ្នកទិញបន្តតែប៉ុណ្ណោះ ។ ឃើញថាជនជាប់ចោទទាំងពីរនាក់នេះជាអ្នកធ្វើចរាចរណ៍រូបិយវត្ថុ និង រូបិយប័ណ្ណក្លែងបន្លំ ។

៥-ជនជាប់ចោទ [redacted] ផាន ឆ្លើយនាពេលសវនាការនេះថា ខ្លួនបានទទួលក្រដាសប្រាក់ប៉ាន់ ១០ដុល្លា- ១០០០០៛ ដើម្បីយកទៅបង្ហាញ(ប៉ាន់)អ្នកទិញតែម្តងគត់ ហើយខ្លួនឈប់ប្រព្រឹត្ត និង ហាមកូនឈ្មោះ [redacted] សារ៉ាត់ ឱ្យឈប់ប្រព្រឹត្តទៀត ។ ខ្លួនសុំបន្ធូរបន្ថយទោស ពីព្រោះខ្លួនចាស់ហើយ និង ដឹងខុស ។ គប្បីពិចារណា ។

៦-សាលក្រមព្រហ្មទណ្ឌលេខៈ១១ ក្រ១ ចុះថ្ងៃ១៥.២.២០១១ របស់សាលាដំបូងរាជធានីភ្នំពេញមានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុចផ្តន្ទាទោសឈ្មោះ [redacted] ផាន ត្រូវកែប្រែតាមការយល់ឃើញខាងលើ ។



Scanned with CamScanner

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខៈ ១៦៣ ចុះថ្ងៃ២.៣.២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] ផាន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងបណ្ដឹងឧទ្ធរណ៍លេខៈ ១២៤-១២៥-១២៦ ចុះថ្ងៃ២២.២.២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] គៀង, [redacted] សារ៉ាត់ និង [redacted] សុខហ៊ី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ១១ ក្រ១ ចុះថ្ងៃទី១៥-២-២០១១របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែការផ្ដន្ទាទោសឈ្មោះ [redacted] ផាន ដាក់ពន្ធនាគារ៨ឆ្នាំ កែប្រែមកជា៥ឆ្នាំ គិតពីថ្ងៃឃុំខ្លួន២.៧.២០១០វិញ ។ ចំណុចផ្សេងទៀតតម្កល់ទុកដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៤-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ [redacted] គាង-[redacted] សារ៉ាត់-[redacted] សុខហ៊ី ចំពោះមុខ [redacted] ផាន និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

បើកផ្លូវប្ដឹងទាស់ និង សាទុក្ខ តាមកំណត់ច្បាប់ ។

សាលដីកាស្ពាពរនេះ ចូលជាស្ពាពរចំពោះឈ្មោះ [redacted] សារ៉ាត់ ។

<u>សេចក្ដីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ច គ្រប់ថ្នាក់ គ្រប់តំណែង និងកំលាំងប្រដាប់អាវុធ ជួយសហការ អនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់</u> ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី[illegible]..ឆ្នាំ២០១៤

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]